ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២៣៤ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០០២

## ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតរបបគណនេយ្យបុរេប្រទាន
## នៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

- ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- លេខាធិការ នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែ ប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ៨២ អ.ន.ក្រ.ប.ក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទ បញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការអនុវត្តន៍បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ស.ហ.វ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរបបគណនេយ្យបុរេប្រទាន

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855 23 724 664 Fax: 855 23 427 798

-បានឃើញប្រកាសលេខ១២៩ ប្រក.សហវ ចុះថ្ងៃទី ០៩ ខែមេសា ឆ្នាំ១៩៩៧ ស្តីពីការកំនត់ទឹកប្រាក់ រង្វាន់មេធាវីស្ម័គ្រចិត្ត១១ សំរាប់ទូទាត់ចំណាយចាំបាច់ ទៅលើដំណើរការរដ្ឋបាលសំភារៈ និង ផ្សព្វផ្សាយ ។

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

## សំរេច

ប្រការ១ :ត្រូវបានបង្កើតរង្វាន់មេធាវីស្ម័គ្រចិត្ត១១ នៅលេខាធិការដ្ឋាន ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ដើម្បី ទូទាត់ចំណាយទាំងឡាយណាដែលមានចែងក្នុងមាត្រា៦៤នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅ នៃគណនេយ្យសាធារណៈ។ ចំនួនទឹកប្រាក់ជាអតិបរិមា នៃការចំណាយដែលអនុញ្ញាត អោយរង្វាន់មេធាវីស្ម័គ្រចិត្ត ធ្វើការទូទាត់ ត្រូវ កំណត់ក្រោមក្រោម ៥០០.០០០,០០ (ប្រាំរយពាន់រៀលគត់) តាមចំណាត់ថ្នាក់ចំណាយនីមួយៗ ដូចមានចែងក្នុងតារាង ឧបសម្ព័ន្ធ ភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

ប្រការ២ :ចំនួនទឹកប្រាក់ នៃរង្វាន់មេធាវីស្ម័គ្រចិត្ត១១ សំរាប់មួយឆ្នាំនៃឆ្នាំ ត្រូវបានកំណត់ត្រឹម ចំនួន ១០.៥០០.០០០,០០ (ដប់លានប្រាំរយពាន់រៀលគត់) ។

ប្រការ៣ :អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ត្រូវទទួលបន្ទុក អនុវត្តតាម ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

អគ្គលេខាធិការ
ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

ឡៀល មុន

ចម្លងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ